ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៩៥ ព.ណ.ន.ស.ជ.ប្រក

# ប្រកាស
## ស្ដីពី
## បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះអំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានដើមកំណើតទំនិញ
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-** គោលបំណង

ប្រកាសនេះកំណត់អំពីវិធាន បែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលចំពោះបុគ្គលប្រព្រឹត្តអំពើល្មើសដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ក្នុងគោលបំណងលើកកម្ពស់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញឱ្យកាន់តែមានប្រសិទ្ធភាព។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

**ប្រការ២ _ វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដាក់ទណ្ឌកម្មរដ្ឋបាល លើបុគ្គលប្រព្រឹត្តអំពើល្មើសតាមច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញ និងមន្ត្រីមានសមត្ថកិច្ចដែលអនុវត្តផ្ទាល់ក្នុងវិជ្ជាជីវៈ ដូចមានកំណត់ក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

**ប្រការ៣ _ និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **បុគ្គលប្រព្រឹត្តអំពើល្មើស** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសនឹងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២- **បុគ្គលរងទណ្ឌកម្ម** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសនឹងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយទទួលរងទណ្ឌកម្មរដ្ឋបាលពីក្រសួងពាណិជ្ជកម្ម។

៣- **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីដែលផ្តល់សេវាសាធារណៈ និងមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ឬអង្គភាពផ្សេងទៀតដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី២
## ទណ្ឌកម្មរដ្ឋបាល

**ប្រការ៤ _ ប្រភេទនៃទណ្ឌកម្មរដ្ឋបាល**

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម
- ការព្យួរ ការដកហូត ឬលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និង
- ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានជាធរមាន។

**ប្រការ៥ _ ការព្រមានជាលាយលក្ខណ៍អក្សរ**

ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលបុគ្គលពុំបានបំពេញកាតព្វកិច្ចណាមួយតាមការតម្រូវដូចមានកំណត់ក្នុងប្រកាសស្តីពីនីតិវិធីក្នុងការស្នើសុំនិងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ របស់ក្រសួងពាណិជ្ជកម្ម និងបទប្បញ្ញត្តិជាធរមានដូចខាងក្រោម៖

- ការបំពេញឧបសម្ព័ន្ធបញ្ជាក់ដើមកំណើតទំនិញ ឬការស្នើសុំលិខិតអនុញ្ញាតបញ្ជាក់ដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលមិនមានតម្រូវការវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ
- ការផ្តល់ឯកសារសម្រាប់ផ្ទៀងផ្ទាត់ និងតម្កល់ទុក
- ការជូនដំណឹងស្តីពីសកម្មភាពផលិតកម្ម និងការនាំចេញ
- ឯកសារតម្រូវក្នុងការប្រកាស និងផ្ទៀងផ្ទាត់គុណភាពសន្និធិវត្ថុធាតុដើម។

ការព្រមានជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវកំណត់ឱ្យមានចំនួនពីរលើក ដោយក្នុងមួយលើកអាចកំណត់រយៈពេលអប្បរមាចំនួន ៣០ (សាមសិប) ថ្ងៃ និងអតិបរមាចំនួន ៩០ (កៅសិប) ថ្ងៃ ផ្អែកតាមស្ថានភាពនៃបទល្មើស។

**ប្រការ៦ _ ការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម**

ក្នុងករណីបុគ្គលរងទណ្ឌកម្មដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ នៅតែបន្តប្រព្រឹត្តអំពើល្មើស បុគ្គលរងទណ្ឌកម្មនោះត្រូវរងនូវការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

ការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ត្រូវកំណត់រយៈពេលអប្បបរមាចំនួន ៣០ (សាមសិប) ថ្ងៃ និងអតិបរមាចំនួន ១៨០ (មួយរយប៉ែតសិប) ថ្ងៃ ផ្អែកតាមស្ថានភាពនៃបទល្មើស។

**ប្រការ៧ _ ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ**

ក្នុងករណីបានទទួលរងនូវការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម ហើយបុគ្គលរងទណ្ឌកម្មនេះនៅតែបន្តប្រព្រឹត្តអំពើល្មើស ដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ ត្រូវរងនូវការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ។

**ប្រការ៨ _ ការដាក់ទណ្ឌកម្មមន្ត្រីមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ច ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវរងទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

## ជំពូកទី៣
## សមត្ថកិច្ច និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល

**ប្រការ៩ _ សមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេត**

មន្ត្រីស៊ើបអង្កេតត្រូវជ្រើសរើសចេញពីអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យអំពើល្មើស ពាក់ព័ន្ធនឹងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ និងបទប្បញ្ញត្តិជាធរមាន។

រាល់ការចាប់ផ្តើមនីតិវិធីស៊ើបអង្កេត និងការដាក់ទណ្ឌកម្មរដ្ឋបាលចំពោះបុគ្គលប្រព្រឹត្តអំពើល្មើស ត្រូវមានគោលការណ៍អនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ១០ _ សិទ្ធិរបស់បុគ្គលប្រព្រឹត្តអំពើល្មើស**

បុគ្គលប្រព្រឹត្តអំពើល្មើស ឬអ្នកតំណាង មានសិទ្ធិបកស្រាយបំភ្លឺ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ មកមន្ត្រីស៊ើបអង្កេត។

ការគេចវេះក្នុងការស្រាយបំភ្លឺ ត្រូវសន្មត់ថាជាការទទួលស្គាល់អំពើល្មើសដែលបានប្រព្រឹត្ត។

**ប្រការ១១ _ ការបញ្ជូនសេចក្តីសម្រេច**

មន្ត្រីស៊ើបអង្កេត អាចបញ្ជូនសេចក្តីសម្រេចស្តីអំពីការដាក់ទណ្ឌកម្មរដ្ឋបាល ទៅគេហដ្ឋាន ឬទីស្នាក់ការក្រុមហ៊ុនរបស់បុគ្គលទទួលរងទណ្ឌកម្មដោយផ្ទាល់ ឬតាមប្រៃសណីយ៍ ឬតាមទំនាក់ទំនងអេឡិចត្រូនិក។

ក្នុងករណីដែលបុគ្គលទទួលរងទណ្ឌកម្ម មិនព្រមទទួលយកសេចក្តីសម្រេចអំពីការដាក់ទណ្ឌកម្មនេះ ឬមិនមានបុគ្គលទទួល មន្ត្រីស៊ើបអង្កេតអាចបិទផ្សាយសេចក្តីសម្រេចអំពីការដាក់ទណ្ឌកម្មនៅគេហដ្ឋាន ឬទីស្នាក់ការក្រុមហ៊ុនរបស់បុគ្គលទទួលរងទណ្ឌកម្ម ឬសាលាឃុំ-សង្កាត់ ឬផ្សព្វផ្សាយជាសាធារណៈ។ សេចក្តីសម្រេចដែលបានបិទផ្សាយ ឬផ្សព្វផ្សាយរួច ត្រូវបានចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលរងទណ្ឌកម្ម។

**ប្រការ១២ _ ស្ថានទម្ងន់ និងស្ថានសម្រាល នៃការដាក់ទណ្ឌកម្ម**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អាចចេញសេចក្តីសម្រេចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាលដោយពិនិត្យលើស្ថានទម្ងន់ និងស្ថានសម្រាល នៃការប្រព្រឹត្តអំពើល្មើស ដូចខាងក្រោម៖

**ក- ត្រូវបានចាត់ចូលជាស្ថានទម្ងន់នៃការប្រព្រឹត្តអំពើល្មើស នៅពេលដែលបុគ្គលប្រព្រឹត្តអំពើល្មើស៖**

- ប្រព្រឹត្តដោយមានការគិតទុកជាមុន
- ប្រព្រឹត្តអំពើល្មើសច្រើនដង ឬបន្តបន្ទាប់
- បង្ខិតបង្ខំ ឬគំរាមកំហែងទៅលើបុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តអំពើល្មើស



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

- ប្រព្រឹត្តអំពើល្មើសដោយរំលោភតួនាទី និងអំណាចរបស់បុគ្គលដទៃ
- បន្តប្រព្រឹត្តអំពើល្មើសទោះបីជាបុគ្គលនោះត្រូវបានតម្រូវឱ្យបញ្ឈប់នូវអំពើល្មើសនោះ
- ប្រព្រឹត្តអំពើល្មើសក្នុងអំឡុងពេលដែលបុគ្គលនោះ កំពុងស្ថិតក្នុងដំណាក់កាលនៃការអនុវត្តវិធានការទណ្ឌកម្មរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ឬ
- មានការលាក់បំបាំងការប្រព្រឹត្តអំពើល្មើស។

**ខ- ត្រូវបានចាត់ចូលជាស្ថានសម្រាលនៃការប្រព្រឹត្តអំពើល្មើស នៅពេលដែលបុគ្គលប្រព្រឹត្តអំពើល្មើស៖**

- មានឆន្ទៈក្នុងការកែតម្រូវ
- បានរាយការណ៍អំពីការប្រព្រឹត្តអំពើល្មើស និងសារភាពអំពីកំហុស ឬ
- បានប្រព្រឹត្តអំពើល្មើសដោយសារការបង្ខិតបង្ខំ ឬគាបសង្កត់ពីបុគ្គលផ្សេងទៀត។

### ប្រការ១៣ .- ការប្ដឹងតវ៉ា

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល អាចដាក់ពាក្យប្ដឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានការសម្រេចពីការដាក់ទណ្ឌកម្មនោះ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវធ្វើសេចក្ដីសម្រេចចំពោះបណ្ដឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃដែលទទួលបានពាក្យបណ្ដឹងតវ៉ា។

ក្នុងករណីដែលបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បុគ្គលនោះអាចដាក់ពាក្យប្ដឹងទៅតុលាការ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើបណ្ដឹងតវ៉ានោះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

### ប្រការ១៤ .-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាននាំចេញ នាំចូល ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញក្នុងតំបន់សេដ្ឋកិច្ចពិសេស ប្រធានគ្រប់នាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២រោច ខែ បុស្ស ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ១៤

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ